1

ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខៈ ៣៦០ប្រ

ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២ **នាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ១២៨ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧ខែឧសភាឆ្នាំ២០០៣

ចុះថ្ងៃទី២៧ខែឧសភាឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២-លោក វៀល មួន ជាចៅក្រម

៣-លោក ស៊ិន ឌឹម ជាចៅក្រម

៤-លោក ប្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៥-លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

លោក **ស៊ិន នារៈ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៤៧"ឈ" ចុះថ្ងៃទី ២៦ ខែមិនា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ រវាង :

ដើមចោទឈ្មោះ **លូ យៀវឃីន** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មុខរបរកសិពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៣ z ផ្លូវលេខ ១៨៤ ក្រុម២៧ សង្កាត់ផ្សារដេប៉ូ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យឈ្មោះទេព សុជាតិ ភេទប្រុស ទីលំនៅសព្វថ្ងៃផ្ទះលេខ ៨អឺ១ ផ្លូវ១៨៦ ក្រុម៣៥ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

ចុងចំលើយឈ្មោះ **ខាន់ សាវឿន** (ដើមបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមហ៊ុន ទីលំនៅសព្វថ្ងៃផ្ទះលេខ ៣៨អឺសូន្យ ផ្លូវប៉ាស្ទ័រ សង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

<u>**កម្មវត្ថុបណ្តឹង**</u> : ប្តឹងឃាត់មិនឱ្យអ្នកអនុវត្តសាលក្រមប្រគល់ប្រាក់ឱ្យទៅអ្នកតំណាង

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦០ប្រ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ១៨១ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២របស់ឈ្មោះចាន់សារឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៧"ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

តាមសាលដីកាស្តាពរលេខ ២១"ង"ចុះថ្ងៃទី១៧-០២-២០០០ ចុងចំលើយឈ្មោះចាន់សារឿន បានធ្វើជាតំណាងឱ្យឈ្មោះលូ យៀវឃីន និងក្រុមហ៊ុនថៃរ៉ុងអាំងទែរណាស្យូណាល់ ហើយដែលបានប្តឹងទារប្រាក់ពីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ថ្លៃកក់ឈើ ដែលជាប្រាក់របស់ឈ្មោះ លូ យៀវឃីន (ក្រុមហ៊ុនអាំងទែរណាស្យូណាល់) ហើយតុលាការបានសំរេចចូលជាស្តាពរ គឺបង្គាប់ឱ្យបង្វែរប្រាក់កក់ទៅលោកចាន់ សារឿន តំណាងឱ្យក្រុមហ៊ុន អាំងទែរណាស្យូណាល់)វិញ ។

ពេលអនុវត្តសាលដីកាស្តាពរឈ្មោះលូ យៀវឃីន (ក្រុមហ៊ុនអាំងទែរណាស្យូណាល់) ដែលជាម្ចាស់ប្រាក់ បានដាក់ពាក្យប្តឹងចុះថ្ងៃទី០៣-៨-២០០១ ទៅតុលាការក្រុងភ្នំពេញ ដើម្បីទារប្រាក់ពីឈ្មោះចាន់សារឿន និងសុំឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្វែរប្រាក់ដែលអនុវត្តតាមសាលដីកាស្តាពរឱ្យមកខ្លួនវិញ ព្រោះថា ជាប្រាក់របស់ខ្លួន រីឯឈ្មោះចាន់ សារឿន គ្រាន់តែជាអ្នកតំណាងឱ្យខ្លួន និង អ្នករត់ការឱ្យក្រុមហ៊ុនប៉ុណ្ណោះ ។

តាមបណ្តឹងកិច្ចការប្រញាប់ ចុះថ្ងៃទី ០៣-៨-២០០១ របស់ឈ្មោះលូ យៀវឃីនថា : ឈ្មោះចាន់ សារឿន ជាអ្នកតំណាងរត់ការអោយខ្លួន ហើយបានទទួលប្រាក់ពីខ្លួនចំនួន ០៥លើក សរុប ២១១.០៨៤,៦៥៦ដុល្លាអាមេរិក សំរាប់យកទៅកក់ និងដេញថ្លៃឈើធ្លង់ចំនួន៥៩៩,១២២ម៉ែត្រគូប តែមិនបានសំរេច ហើយបានសងមកខ្លួនវិញ ចំនួន ៧០.០០០ដុល្លាអាមេរិក រួចនៅជំពាក់ខ្លួនចំនួន ១៤១.០៨៤,៦៥៦ដុល្លាអាមេរិក ។ ក្នុងនាមតំណាងឱ្យក្រុមហ៊ុន ឈ្មោះចាន់ សារឿន បានប្តឹងទារប្រាក់កក់ឈើពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ ហើយតាមសាលដីកាស្តាពរលេខ ២១"ង" ចុះថ្ងៃទី១៧ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍បានសំរេចឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សងប្រាក់ទៅក្រុមហ៊ុនថៃរ៉ុងអាំងទែណាស្យូណាល់(ចាន់ សារឿន) ចំនួន៩៥.០០០ដុល្លាអាមេរិក ។ ខ្លួនបានទារប្រាក់ពីលោកចាន់ សារឿន វិញ ជាច្រើនលើក ហើយឈ្មោះចាន់ សារឿន បានគេចវេសរហូត ដែលជាហេតុនាំឱ្យខ្លួនមានការភ័យបារម្ភខ្លាចលោក ចាន់ សារឿន នៅពេលអនុវត្តតាមសាលដីកាលេខ ២១"ង"បានប្រាក់ហើយ មិនយកប្រាក់មកសងខ្លួន ។ ហេតុនេះខ្លួនសូមឱ្យតុលាការហាមឃាត់អ្នកអនុវត្តសាលដីកាជាបណ្តោះអាសន្នសិន ក្នុងការប្រគល់ប្រាក់ឱ្យចាន់ សារឿននោះ ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ២១ប្រ"ង" ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០១ ទុកជាត្រឹមត្រូវ

តាមទំរង់ និងគតិច្បាប់ ។

២-ហាមឃាត់ជាបណ្តោះអាសន្នដល់អ្នកអនុវត្តសាលដីការដ្ឋប្បវេណីលេខ ២១"ង"ចុះថ្ងៃទី១៧-០២-២០០០ របស់សាលាឧទ្ធរណ៍ ក្នុងការប្រគល់ប្រាក់ដែលបានមកពីការអនុវត្តសាលដីកានេះឱ្យទៅឈ្មោះចាន់ សារឿន ជាបណ្តោះអាសន្នសិន ដើម្បីរង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។

៣-បង្គាប់ឱ្យភាគីដើមចោទបង់ប្រាក់ប្រដាប់ក្តីចំនួន ៤.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ២.០០០៛ សរុប ៤.០០០៛ តែប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចជាស្រេច ។

៤-ដីកាសំរេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥-ដីកាសំរេចនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចំលើយ ។ ទុកសិទ្ធិឱ្យប្តឹងទាស់១៥ថ្ងៃ គិតពីថ្ងៃឱ្យដំណឹងនិងប្តឹងឧទ្ធរណ៍ពីរខែ គិតពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៨"ង" ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះពុធ ធារី ជាមេធាវីការពារឱ្យចុងចំលើយឈ្មោះ ចាន់ សារឿន ប្តឹងមិនសុខចិត្តនឹងដីកាសំរេចកិច្ចការប្រញាប់លេខ ២១ប្រ"ង" ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាកិច្ចការប្រញាប់លេខ ៤៧"ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-១០-២០០១ របស់លោកមេធាវីពុធ ធារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់ដីកាសំរេចកិច្ចការប្រញាប់លេខ២១ប្រ"ង" ចុះថ្ងៃទី២៤-៨-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ១៣.០០០៛ គឺ ពន្ធហ្វ៊ីង និង ពន្ធចុះបញ្ជីក្តី២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខតំណាងដើមចោទ កំបាំងមុខចុងចំលើយ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៨១ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២របស់ឈ្មោះចាន់សារឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៧"ឈ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា : សាលដីកាសាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះទេព សុជាតិ តំណាងឱ្យដើមចោទឈ្មោះលូ យៀវឃីន នាពេលសវនាការថា : ប្រាក់ដែលសំរាប់កក់ឈើ និង នាំឈើចេញជាប្រាក់របស់ក្រុមហ៊ុនទាំងអស់ រីឯឈ្មោះចាន់ សារឿនគ្រាន់តែជាអ្នកតំណាងឱ្យក្រុមហ៊ុនសំរាប់រត់ការជំនួសឱ្យក្រុមហ៊ុនប៉ុណ្ណោះ ។ មូលហេតុដែលក្រុមហ៊ុនប្តឹងឃាត់មិនឱ្យប្រគល់ប្រាក់ឱ្យឈ្មោះ ចាន់ សារឿន ព្រោះក្រុមហ៊ុនពុំមានការទុកចិត្ត ។ ម៉្យាងទៀតលោកចាន់ សារឿនបានទទួលលុយ៥លើក ចំនួនជាង៩ម៉ឺនដុល្លាអាមេរិក ខ្លួនសុំអោយលោកចាន់ សារឿនបង្វែរលុយ៩ម៉ឺនជាងមកឱ្យខ្លួនវិញ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចំលើយរបស់លោកទេព សុជាតិ ជាតំណាងដើមចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៨១ចុះថ្ងៃទី១៧-៥-២០០២ របស់លោកចាន់សារឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ក្នុងពាក្យបណ្តឹងអង្គសេចក្តីចុះថ្ងៃទី ០៣-៨-២០០១ លោកលូ យៀវឃីន ប្រធានក្រុមហ៊ុនថៃរ៉ុងអាំងទែណាស្យូណាល់ បានប្តឹងសុំដកសិទ្ធិពីលោកចាន់ សារឿន ជាតំណាងឱ្យក្រុម-ហ៊ុនថៃរ៉ុងអាំងទែណាស្យូណាល់ក្នុងរឿងក្តីគ្រប់ជាន់ថ្នាក់ ។ ដូច្នេះតុលាការគប្បីហាមឃាត់ប្រាក់អនុវត្តសាលក្រមរង់ចាំរឿងអង្គសេចក្តីចូលជាស្ថាពរសិន ។

- យល់ឃើញថា តុលាការកំពូលបានបង្គាប់ឱ្យលោកចាន់ សារឿនធ្វើសារណា និង បានកោះហៅឱ្យមកចូលរួមសវនាការនេះហើយ ប៉ុន្តែលោកពុំបានធ្វើសារណានិងពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខតំណាងដើមចោទ

## កំបាំងមុខចុងចំលើយប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ១៨១ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០០២ របស់

លោក ចាន់ សារឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៧ "ឃ" ចុះថ្ងៃទី ២៦ ខែមិនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦០ប្រ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការកំពូលទៅ តុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ដែលលោកចាន់ សារឿន បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៣ ។